# ខមាទោសចំពោះព្រះរតនៈត្រ័យ បាលី ប្រែ

ឧត្តមង្គេន វន្ទេហំ បាទបំសុំ វរុត្តមំ

ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវល្អងធូលីព្រះបាទនៃព្រះសម្មាសម្ពុទ្ធដ៏ប្រសើរខ្ពង់ខ្ពស់ ដោយអវយវៈដ៏ឧត្តមគឺត្បូង

ពុទ្ធេ យោ ខលិតោ ទោសោ

ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះពុទ្ធជាម្ចាស់

ពុទ្ធោ ខមតុ តំ មមំ

សូមព្រះពុទ្ធជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

ឧត្តមង្គេន វន្ទេហំ ធម្មញ្ច ទុវិធំ វរំ

ខ្ញុំព្រះករុណាសូមថ្វាយបង្គំនូវព្រះធម៌ដ៏ប្រសើរមានពីរប្រការ គឺព្រះបរិយត្តិធម៌និងព្រះនព្វលោកុត្តរធម៌ ដោយអវយវៈដ៏ឧត្តមគឺត្បូង

ធម្មេ យោ ខលិតោ ទោសោ

ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះធម៌ជាម្ចាស់

ធម្មោ ខមតុ តំ មមំ

សូមព្រះធម៌ជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។

ឧត្តមង្គេន វន្ទេហំ សង្ឃញ្ច ទុវិធោត្តមំ

ខ្ញុំព្រះករុណា សូមថ្វាយបង្គំនូវព្រះសង្ឃដ៏ប្រសើរមានពីរប្រការ គឺសម្មតិសង្ឃនិងអរិយសង្ឃដោយអវយវៈដ៏ឧត្តមគឺត្បូង

សង្ឃេ យោ ខលិតោ ទោសោ

ទោសឯណាដែលខ្ញុំព្រះករុណាធ្វើឱ្យភ្លាំងភ្លាត់ហើយក្នុងព្រះសង្ឃជាម្ចាស់

សង្ឃោ ខមតុ តំ មមំ

សូមព្រះសង្ឃជាម្ចាស់អត់នូវទោសនោះដល់ខ្ញុំព្រះករុណា។



ដកស្រង់និងចងក្រងដោយខ្ញុំបាទ **ឌាន់ អ៊ុច** អាចារ្យទី១សម្រាប់វត្តធម្មារាម ក្រុងស្តុកតុន រដ្ឋកាលីហ្វរនីញ៉ា ព.ស.២៥៤៣
វាយចម្លងដោយនាងខ្ញុំ ប៉ុក សារ៉េង ថ្ងៃទី២៧ ខែមីនា គ.ស.២០១២ * ពិនិត្យហើយនិងដាក់គេហទំព័រវត្តដោយខ្ញុំបាទ **អ៊ិន លី**